
អក្ខរវិធី និង ធម៌នមស្ការ

# មន្តវិធី និង ធម៌ឧទ្ទិស



រៀបរៀងដោយ

ភិក្ខុវជិរប្បញ្ញោ សាន សុជា

សម្រាប់ជាធម្មទាន

# មាតិកាអត្ថបទ


ឈ្មោះធម៌ ទំព័រ

ពាក្យបំភ្លឺ ........................................ ក

អក្ខរវិធី ........................................ ១

ធម៌នមស្ការ ........................................ ១៦

ឯកឧត្តបាលី និងសេចក្តីប្រែ .............................. ៨៣

នាទីកំណាព្យផ្សេងៗ ................................ ១១០

អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ..... ១៣៣

សៀវភៅដែលធ្លាប់បានរៀបរៀង ........... ១៣៤

កម្មវិធីផ្សព្វផ្សាយព្រះធម៌តាមវិទ្យុ........ ១៣៦

# ពាក្យបំភ្លឺ

ការនមស្ការព្រះរតនត្រៃ គឺជាការងារដ៏ប្រសើរបំផុត ដែលពុទ្ធបរិស័ទគប្បីប្រព្រឹត្ត ប្រតិបត្តិប្រចាំថ្ងៃ មុនពេលដែលចេញទៅបំពេញកិច្ចការងារ និងមុនពេលចូលទទួលទានដំណេក ។

ដោយហេតុនេះឯង ទើបខ្ញុំរៀបរៀងកូនសៀវភៅ នេះចែកជូនជាធម្មទាន ដើម្បីពុទ្ធបរិស័ទងាយដាក់ជាប់ទៅតាមខ្លួន ហើយដើម្បីជំនួយដល់ពុទ្ធបរិស័ទ ដែលមិនទាន់ចេះអានភាសាបាលី ទើបខ្ញុំសរសេរពន្យល់អំពីអក្ខរវិធីក្នុងភាសាបាលីដោយសង្ខេបរៀងទុកខាងដើមជាមុន ។

ដោយអំណាចនៃធម្មទាននេះ សូមឲ្យសុខសន្តិភាព បានជ្រាបចូលក្នុងសន្តានចិត្តនៃសព្វសត្វក្នុងត្រៃភព ។

*សាលាសិក្សាព្រះធម៌ ឃុំកំពង់ចិនត្បូង ស្រុកស្ទោង*
*ខេត្តកំពង់ធំ ប្រទេសកម្ពុជា*
*ថ្ងៃសុក្រ ១៥ កើត ខែជេស្ឋ អដ្ឋស័ក ព.ស.២៥៥០*

**ភិក្ខុវជិរប្បញ្ញោ សាន-សុជា**

# អក្ខរវិធី

## អក្ខរៈ (អក្សរ) ក្នុងភាសាបាលី

## មាន ៤១ តួ

## ស្រៈ មាន ៨ តួ គឺ

ស្រៈពេញតួ អ អានថា អាក់ ឬ អៈ

អា អានថា អា

ឥ អានថា អ៊ិ

ឦ អានថា អ៊ី

ឧ អានថា អ៊ុ

ឩ អានថា អ៊ូ

ឯ អានថា អេ

ឱ អានថា អោ

ព្យញ្ជនៈមាន ៣៣ តួ គឺ

ក អានថា កាក់ ឬ កៈ

ខ អានថា ខាក់ ឬ ខៈ

គ អានថា គាក់ ឬ គៈ

ឃ អានថា ឃាក់ ឬ ឃៈ

ង អានថា ងាក់ ឬ ងៈ

ច អានថា ចាក់ ឬ ចៈ

ឆ អានថា ឆាក់ ឬ ឆៈ

ជ អានថា ជាក់ ឬ ជៈ

ឈ អានថា ឈាក់ឬ ឈៈ

ញ អានថា ញាក់ ឬ ញៈ

ដ អានថា ដាក់ ឬ ដៈ

ឋ អានថា ឋាក់ ឬ ឋៈ

ឌ អានថា ឌាក់ ឬ ឌៈ

ឍ អានថា ឍាក់ ឬ ឍៈ

ណ អានថា ណាក់ឬ ណៈ

ត អានថា តាក់ ឬ តៈ

ថ អានថា ថាក់ ឬ ថៈ

ទ អានថា ទាក់ ឬ ទៈ

ធ អានថា ធាក់ ឬ ធៈ

ន អានថា នាក់ ឬ នៈ

ប អានថា ប៉ាក់ ឬ ប៉ៈ

ផ អានថា ផាក់ ឬ ផៈ

ព អានថា ពាក់ ឬ ពៈ

ភ អានថា ភាក់ ឬ ភៈ

ម អានថា មាក់ ឬ មៈ

យ អានថា យាក់ ឬ យៈ

រ អានថា រាក់ ឬ រះ

ល អានថា លាក់ ឬ លះ

វ អានថា វាក់ ឬ វះ

ស អានថា សាក់ ឬ សះ

ហ អានថា ហាក់ ឬ ហះ

ឡ អានថា ឡាក់ ឬ ឡះ

ំ អានថា អាំង



# ស្រៈទាំង៨តួ កាលប្រើជាស្រៈនិស្ស័យ

## មានរូបដូច្នេះ

អ > | ផ្សំនឹងព្យញ្ជនៈក ទៅជា ក[១]

អា > -ា ផ្សំនឹងព្យញ្ជនៈក ទៅជា កា

ឥ > -ិ ផ្សំនឹងព្យញ្ជនៈក ទៅជា កិ

ឦ > -ី ផ្សំនឹងព្យញ្ជនៈក ទៅជា កី

ឧ > -ុ ផ្សំនឹងព្យញ្ជនៈក ទៅជា កុ

ឩ > -ូ ផ្សំនឹងព្យញ្ជនៈក ទៅជា កូ

ឯ > េ- ផ្សំនឹងព្យញ្ជនៈក ទៅជា កេ

ឱ > េ-ា ផ្សំនឹងព្យញ្ជនៈក ទៅជា កោ

---

១-អានថា កាក់ ឬ កៈ

# ស្រះចែកចេញជាពីរប្រភេទ

## ១-ស្រះរស្សៈ (សម្លេងខ្លី) មាន ៣ គឺ

អ ឥ ឧ

| ិ ុ

ស្រៈទាំង៣តួនេះ ទោះនៅជាស្រៈពេញតួក្តី ក្លាយទៅជាស្រៈនិស្ស័យក្តី ពេលអាន ត្រូវមាន សម្លេងខ្លី ។

ឧទាហរណ៍ អវិជ្ជា, ពហូ, ឥទានិ, តិនុគ្គោ, ឧទបាទិ, សុភាសិតា ..... ។

២-ស្រះទីឃៈ (សម្លេងវែង) មាន ៥ គឺ

អា ឦ ឩ ឯ ឱ

-ា ី ូ េ ោ

ស្រះទាំង៥តួនេះ ទោះនៅជាស្រះពេញតួក្តី ក្លាយទៅជាស្រះនិស្ស័យក្តី ពេលអាន ត្រូវមាន សម្លេងវែង ៗ ។

<u>ឧទាហរណ៍</u> អាចរិយំ, អគារំ, ឦទិសោ, តីណិ, ឩមិ, ទូរតោ, ឯកតោ, ទេវេសុ, ឱកិរតុ, សោភណំ .... ។

## ឃោសាឃោសៈ

### អឃោសៈ

ព្យញ្ជនៈអឃោសៈមាន ១១ តួ គឺ **ក ខ ច ឆ ដ ឋ ត ថ ប ផ** និង **ស**។

ព្យញ្ជនៈអឃោសៈទាំង ១១ តួនេះ ជាព្យញ្ជនៈមានសម្លេងមិនគឹកកង មិនថាស្ថិតនៅខាងមុខ ឬខាងក្រោយព្យញ្ជនៈណាក៏ដោយ ក៏មិនដែលប្រែសម្លេង ទៅតាមព្យញ្ជនៈដទៃទេ គឺនៅតែរក្សាសម្លេងជាអឃោសៈដដែល ដូចជា **វាចា** អានថា វ៉ាចា គឺថា **ចា**

មិនមែនក្លាយទៅជាមានសម្លេង **ឱ** តាមអំណាច **អា** ឡើយ ហើយថែមទាំងអាចទាញសម្លេងព្យញ្ជនៈឃោសៈខ្លះ ឱ្យដួលទៅតាមខ្លួនទៀតផង ដូចជា **ករោតុ** អានថា កៈ <u>រ៉ោ</u> តុ, **ខមាបេថ** អានថា ខៈ <u>ម៉ា</u> ប៉េ ថៈ, **ចរណាំ** អានថា ចៈ <u>រ៉ៈ</u> ណាំង, .... ជាដើម ។

## ឃោសៈ

ព្យញ្ជនៈឃោសៈមាន ២១ តួ គឺ **គ ឃ ង ជ ឈ ញ ឌ ឍ ណ ទ ធ ន ព ភ ម យ រ ល វ ហ ឡ** ។

# ព្យញ្ជនៈឃោសៈមាន ២ យ៉ាង

## ១-ឃោសៈប្រែប្រួល

ព្យញ្ជនៈឃោសៈ ១១ តួ គឺ ង ញ ណ ន ម យ រ ល វ ហ ឡ តែងមាន ការប្រែប្រួលទៅជាមានសម្លេងមិនគឹកកង នៅពេលដែលមានព្យញ្ជនៈអឃោសៈ នៅខាងដើម ដូចជា **បមាណំ** តាមសម្លេងដើម គួរអានថា ប៉ះ មា ណាំង ប៉ុន្តែដោយសារមាន **ប** ដែលជាអឃោសៈនៅខាងដើម ក៏ត្រឡប់ទៅជាអានថា ប៉ះ ម៉ា ណាំង ដូច្នេះវិញជាដើម ។

## ២-ឃោសៈមិនប្រែប្រួល

ព្យញ្ជនៈឃោសៈ ១០ តួ គឺ **គ ឃ ង ជ ឈ ញ ឍ ទ ធ ព ភ** ទាំង ១០ តួនេះ ជាព្យញ្ជនៈរឹង មិនចេះប្រែប្រួលសម្លេងទៅតាមការអូសទាញរបស់ព្យញ្ជនៈដទៃឡើយ ទោះបីមានព្យញ្ជនៈអឃោសៈ នៅខាងដើមក៏ដោយ ដូចជា **ភទ្រាចិ** នៅតែមានសម្លេងថា កៈ ទា ចិ មិនមែនក្លាយទៅជាមានសម្លេង កៈ តា ចិ តាមអំណាច **ភ** នៅខាងដើម ដូច្នេះជាដើមឡើយ ។

## ព្យញ្ជនៈសំយោគ

ព្យញ្ជនៈសំយោគ គឺជាព្យញ្ជនៈតម្រួត ពេលអានត្រូវតែសង្កត់ ហើយមានសម្លេងធ្ងន់ យូរ ប្រហាក់ប្រហែលនឹងស្រៈទីឃៈដែរ ដូចជា **សត្ថារ** អានថា សាត់ (សង្កត់-យូរ) តៈ ធា. **សម្មាសតិ** អានថា សាំ (សង្កត់-យូរ) ម៉ា សៈ តិ ............។

## និគ្គហិត

ព្យញ្ជនៈគឺ ం នេះ តែងតែអាស្រ័យនៅលើព្យញ្ជនៈ ឬស្រៈ ហើយមានសម្លេងធ្ងន់យូរដូចសំយោគដែរ ដូចជា **ពុទ្ធំ** អានថា ពុត ធាំង (សង្កត់-យូរ) ដូច្នេះជាដើម ។

# របៀបអាន

# សុបដិបន្នាទិគុណសំយុត្តំ



## កំណត់ចំណាំបន្ថែម

ចំពោះស្រៈទីឃៈ ៣ តួ គឺ **អា ឯ ឱ** ប្រសិនបើមានព្យញ្ជនៈតម្រួតគ្នា ២ តួនៅខាងចុង បែរជាមានសូរខ្លីដូចជារស្សៈទៅវិញ ដូចជា

អេត តៈ កាំង = ខុស

អេត់ តៈ កាំង = ត្រូវ

**អាត្តំ** **ឯត្តកំ** **ឱដ្ឋោ**

**ស្វាក្ខាតោ** **តេត្តឹស** **ហោន្តិ**

ស្វាក់ ខា តោ = ត្រូវ ហោន់ តិ = ត្រូវ

ស្វាក ខា តោ = ខុស ហោន តិ = ខុស

## ធម៌នមស្ការ

(ជាបឋមត្រូវក្រាបថ្វាយបង្គំបីដងសិន)

### <u>ពុទ្ធរតនប្បណាម</u>

**នមោ តស្ស ភគវតោ អរហតោ**

**សម្មាសម្ពុទ្ធស្ស ។** (សូត្រ ៣ ដង)

វីកិរិយា នមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យ-ធមិទាំងពួងដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

(ក្រាបថ្វាយបង្គំម្តង)

យោ សន្និសិន្នោ វរពោធិមូលេ

មារំ សសេនំ មហតឹ វិជេយ្យោ

សម្ពោធិមាគច្ឆិ អនន្តញាណោ

លោកុត្តមោ តំ បណមាមិ ពុទ្ធំ ៗ

ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើននូវព្រះអនាបានស្សតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណាសូម

ក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**យេ ច ពុទ្ធា អតីតា ច**

**យេ ច ពុទ្ធា អនាគតា**

**បច្ចុប្បន្នា ច យេ ពុទ្ធា**

**អហំ វន្ទាមិ សព្វទា ។**

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ និព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបាន

ត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធ ក្នុងភទ្ទកប្បនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ គ្រប់កាលទាំងពួង។

(ក្រាបថ្វាយបង្គំម្តង)

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ៦**

ប្រែ : **ឥតិបិ សោ ភគវា អរហំ**

ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគនិងវចីបយោគ. **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹង នូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ. **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥.

**សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន, **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក, **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន, **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថាបុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន, **សត្ថាទេវមនុស្សានំ** ទ្រង់ព្រះនាមថាសត្ថាទេវ-

មនុស្សនាំ ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ, **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឱ្យត្រាស់ដឹងផង, **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។

(ក្រាបថ្វាយបង្គំម្តង)

រួចត្រូវប្រកាសប្ដេជ្ញាចំពោះព្រះសម្មាសម្ពុទ្ធថា

**នត្ថិ មេ សរណំ អញ្ញំ**

**ពុទ្ធោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ។**

ប្រែ : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ, **ពុទ្ធោ មេ សរណំ វរំ** មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា, **ឯតេន សច្ចវជ្ជេន ហោតុ**

មេ ជយមង្គលំ សូមសិរីសួស្តីជយមង្គល

ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវ

ពាក្យសច្ចៈនេះ ។

រួចហើយត្រូវសូមខមាទោសចំពោះព្រះសម្មាសម្ពុទ្ធថា

**ឧត្តមង្គេន វន្ទេហំ**

**បាទបំសុំ វរុត្តមំ**

**ពុទ្ធេ យោ ខលិតោ ទោសោ**

**ពុទ្ធោ ខមតុ តំ មមំ ។**

ប្រែ ៈ **ឧត្តមង្គេន វន្ទេហំ បាទបំសុំ**

**វរុត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវល្អងធូលី

ព្រះបាទនៃព្រះសម្មាសម្ពុទ្ធ ដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង, **ពុទ្ធេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យភ្លាំងភ្លាត់ហើយ ក្នុងព្រះពុទ្ធជាម្ចាស់, **ពុទ្ធោ ខមតុ តំ មមំ** សូមព្រះពុទ្ធជាម្ចាស់អត់នូវទោស នោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)



## ធម្មរតនប្បណាម

**អដ្ឋង្គិការិយបថោ ជនានំ**

**មោក្ខប្បវេសាយ ឧជូ ច មគ្គោ**

**ធម្មោ អយំ សន្តិករោ បណីតោ**

**និយ្យានិកោ តំ បនមាមិ ធម្មំ ៕**

ប្រែ : ព្រះសទ្ធម្មឯណា ជាធម៌ប្រកប ដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះ ជាធម៌ធ្វើឱ្យត្រជាក់

រម្ងាប់បង់នូវភ្លើងទុក្ខភ្លើងកិលេស ជាធមិដ៏ឧត្តម ជាគុណញុំាងសត្វ ឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះសទ្ធម្មនោះ ដោយគោរព។

(ក្រាបថ្វាយបង្គំម្តង)

**យេ ច ធម្មា អតីតា ច**

**យេ ច ធម្មា អនាគតា**

**បច្ចុប្បន្នា ច យេ ធម្មា**

**អហំ វន្ទាមិ សព្វទា ។**

ប្រែ : ព្រះធមិទាំងឡាយឯណា ដែលជា

ធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លង

ទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌

របស់ព្រះសម្មាសម្ពុទ្ធ នឹងមានមកក្នុងកាលខាង មុខក្តី

ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់

ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វ

ថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវ

ព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**ស្វាក្ខាតោ ភគវតា ធម្មោ**

**សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ**

**ឱបនយិកោ បច្ចត្តំ វេទិតព្វោ**

**វិញ្ញូហីតិ ។**

ប្រែ : **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយល្អ (ធម្មោ ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺ មគ្គ ៤ ផល ៤ និព្វាន ១), **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណញ្ញាណ គឺថា នឹងបានដឹងដោយស្ដាប់ ដោយជឿបុគ្គលដទៃទេនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង.

**អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថា កាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយ-ផលក៏កើតក្នុងលំដាប់គ្នា មិនបានឃឹតយូរឡើយ. **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថា បើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន. **ឱបនយិកោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចនៃភាវនា. **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម

គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

(ក្រាបថ្វាយបង្គំម្តង)

រូបត្រូវប្រកាសប្តេជ្ញាចំពោះព្រះធម៌ថា

**នត្ថិ មេ សរណំ អញ្ញំ**

**ធម្មោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ។**

ប្រែ : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ. **ធម្មោ មេ សរណំ វរំ** មានតែព្រះធម៌ជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់

ខ្ញុំព្រះករុណា, **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

រួចហើយត្រូវសូមខមាទោសចំពោះព្រះធម៌ថា

**ឧត្តមង្គេន វន្ទេហំ**

**ធម្មញ្ច ទុវិធំ វរំ**

**ធម្មេ យោ ខលិតោ ទោសោ**

**ធម្មោ ខមតុ តំ មមំ ។**

ប្រែ : **ឧត្តមង្គេន វន្ទេហំ ធម្មញ្ច**

**ទុតិយំ  ទរំ**  ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តម គឺត្បូង, **ធម្មេ យោ ខលិតោ ទោសោ** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភាំងភ្លាត់ ហើយក្នុងព្រះធម៌ជាម្ចាស់, **ធម្មោ ខមតុ តំ មមំ** សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

## សង្ឃរតនប្បណាម

**សង្ឃោ វិសុទ្ធោ វរទក្ខិណេយ្យោ**

**សន្តិន្ទ្រិយោ សព្វមលប្បហីនោ**

**គុណេហិនេកេហិ សមិទ្ធិបត្តោ**

**អនាសវោ តំ បនមាមិ សង្ឃំ ។**

ប្រែ : ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រិយរម្ងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជាព្រះសង្ឃ

មានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះអរិយសង្ឃនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**យេ ច សង្ឃា អតីតា ច**

**យេ ច សង្ឃា អនាគតា**

**បច្ចុប្បន្នា ច យេ សង្ឃា**

**អហំ វន្ទាមិ សព្វទា ។**

ប្រែ : ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹង

បានសម្រេចមគ្គនិងផល ក្នុងកាលខាងមុខក្តី

ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបាន

សម្រេចមគ្គនិងផល ក្នុងកាលជាបច្ចុប្បន្ននេះក្តី

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃ

ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

**សុបដិបន្នោ ភគវតោ សាវក-**

**សង្ឃោ ឧជុបដិបន្នោ ភគវតោ**

**សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ**

សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ឞ

ប្រែ : សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌.

**ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា.

**ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង.

**សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរ

ដល់សីល សមាធិ បញ្ញា, **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំងឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១, **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃ ដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិ ផល ១ សកទាគាមិមគ្គ ១ សកទាគា-

មិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១, **ឯស ភគវតោ សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័ក នៃព្រះដ៏មានព្រះភាគ, **អាហុនេយ្យោ** លោកគួរ ទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នក មានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូល មកបូជា, **បាហុនេយ្យោ** លោកគួរទទួលនូវ អាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បី ញាតិនិងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយ បង្អោនចូលមកបូជា, **ទក្ខិណេយ្យោ** លោកគួរ

ទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា, **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ, **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្តគឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

(ក្រាបថ្វាយបង្គំម្តង)

រួចត្រូវប្រកាសប្តេជ្ញាចំពោះព្រះសង្ឃថា

**នត្ថិ មេ សរណំ អញ្ញំ**

**សង្ឃោ មេ សរណំ វរំ**

**ឯតេន សច្ចវជ្ជេន**

**ហោតុ មេ ជយមង្គលំ ២**

ប្រែ : **នត្ថិ មេ សរណំ អញ្ញំ** វត្ថុដទៃជាទីពឹងទីរលឹក នៃខ្ញុំព្រះករុណាមិនមានឡើយ,

**សង្ឃោ មេ សរណំ វរំ** មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹងទីរលឹកដ៏ប្រសើររបស់ខ្ញុំព្រះករុណា,

**ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។

រួចហើយត្រូវសូមខមាទោសចំពោះព្រះសង្ឃថា

**ឧត្តមង្គេន វន្ទេហំ**

**សង្ឃញ្ច ទុវិធោត្តមំ**

**សង្ឃេ យោ ខលិតោ ទោសោ**

**សង្ឃោ ខមតុ តំ មមំ ។**

ប្រែ : **ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអវយវៈដ៏ឧត្តម គឺត្បូង. **សង្ឃេ យោ ខលិតោ ទោសោ** ទោស

ឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយ
ក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ ខមតុ តំ មមំ**
សូមព្រះសង្ឃជាម្ចាស់ អត់នូវទោសនោះដល់
ខ្ញុំព្រះករុណា ។

(ក្រាបថ្វាយបង្គំម្តង)

## រតនបណាមសង្ខេប

## ព្រមទាំងបូជាគ្រឿងសក្ការៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(ប្រែដូចមុន)

ឥតិបិ សោ ភគវា អរហំ ។ល។

ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែ : **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺ កិលេសព្រមទាំងវាសនា គឺកាយបយោគនិង វចីបយោគ ។ល។ **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរ ទៅកាន់ត្រៃភពខ្ជាក់ ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើត ទៀត ឡើយ, **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រម ហើយដោយគុណ មានគុណថា អរហំ ជាដើមនោះ

ដោយសិរសាគឺត្បូង. តព្វ ពុទ្ធំ ឥមេហិ

សក្ការេហិ អភិបូជយាមិ ខ្ញុំព្រះករុណា

សូមបូជាចំពោះ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ

ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណ

ប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

ស្វាក្ខាតោ ភគវតា ធម្មោ ឧលខ

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ

ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា

នមាមិ តព្វ ធម្មំ ឥមេហិ សក្ការេហិ

**អភិប្ជយាមិ ២**

ប្រែ : **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌គឺព្រះត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ ។ល។ **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន, **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា

ស្វាក្ខាតោ ជាដើមនោះ ដោយសិរសាគឺត្បូង,

តព្វ ធម្មំ ឥមេហិ សក្ការេហិ

អភិបូជយាមិ ខ្ញុំព្រះករុណា សូមបូជាចំពោះ

នូវព្រះធម៌ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈ

ទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

សុបដិបន្នោ ភគវតោ សាវក-

សង្ឃោ ឧលខ អនុត្តរំ បុញ្ញក្ខេត្តំ

លោកស្សាតិ តំ សុបដិបន្នាទិគុណសំ-

យុត្តំ សង្ឃំ សិរសា នមាមិ តព្វ សង្ឃំ

**ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ប្រែ : **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវ័ក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌ ។ល។

**អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន, **តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះសង្ឃ

ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណ ថា សុបដិបន្នោ ជាដើមនោះ ដោយសិរសាគឺត្បូង, **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

( ក្រាបថ្វាយបង្គំម្តង)

## បណាមគាថា

យោ កប្បកោដីហិបិ អប្បមេយ្យំ

កាលំ ករោន្តោ អតិទុក្ករានិ

ខេទំ គតោ លោកហិតាយ នាថោ

នមោ មហាការុណិកស្ស តស្ស ។

អសម្ពុធំ ពុទ្ធនិសេវិតំ យំ

ភវាភវំ គច្ឆតិ ជីវលោកោ

នមោ អវិជ្ជាទិកិលេសជាលំ

វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

គុណេហិ យោ សីលសមាធិបញ្ញា

វិមុត្តិញ្ញាណប្បត្តីហិ យុត្តោ

ខេត្តញ្ញានានំ កុសលត្ថិកានំ

តម្ពរិយសង្ឃំ សិរសា នមាមិ ៗ

ប្រែ :

យោ កប្បកោដីហិបិ អប្បមេយ្យំ

កាលំ ករោន្តោ អតិទុក្ករានិ

ខេទំ គតោ លោកហិតាយ នាថោ

នមោ មហាការុណិកស្ស តស្ស

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្វា

ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ ។

រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគួរ

បានត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូលើភពឋាន ។

ធ្វើកម្មជាកម្រ សត្វនិករត្រាប់ពុំបាន

តោកយ៉ាកលំបាកប្រាណ

ព្រោះប្រយោជន៍ដល់សព្វសត្វ ។

ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់

ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

**អសម្ពុធំ ពុទ្ធនិសេវិតំ យំ**

**ភវាភវំ គច្ឆតិ ជីវលោកោ**

**នមោ អវិជ្ជាទិកិលេសជាលំ**

**វិទ្ធំសិនោ ធម្មវរស្ស តស្ស**

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កាមជាគោល

ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។

ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម

គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។

នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា

កាត់បង់អវិជ្ជា គឺបណ្ដាញកិលេសហើយ ។

គុណេហិ យោ សីលសមាធិបញ្ញា

វិមុត្តិញាណប្បភូតីហិ យុត្តោ

ខេត្តញ្ញនានំ កុសលត្ថិកានំ

តមរិយសង្ឃំ សិរសា នមាមិ

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល ។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ ។

## ថ្វាយបង្គំសុំសេចក្ដីសុខ

ឥច្ចេវមច្ចន្ត នមស្សនេយ្យំ
នមស្សមានោ រតនត្តយំ យំ

# បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
# តស្សានុភាវេន ហតន្តរាយោ

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។

សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ ។

សូមឱ្យកម្ចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។

ដោយកំម្លាំងអានុភាព បុញ្ញលាភជាប្រធាន

កងបុញ្ញរាសីមាន    សូមបានក្សាន្តកុំមានមោះ ។

ដោយគុណនមស្ការ    ត្រៃរតនាប្រសើរខ្ពស់

សូមអានិសង្សនោះ    ដាក់ដល់ឋាននិព្វានហោង ។

( ក្រាបថ្វាយបង្គំម្តង)

## ពុទ្ធបាទនមស្ការគាថា

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ តិលោកកេតុំ តិភវេកនាថំ យោលោកសេដ្ឋោ សកលំ កិលេសំ ឆេត្វាន ពោធេសិ ជនំ អនន្តំ**

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខ្ញុំសូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្លងផុតអំពីច្រាំងនៃភពហើយ ព្រះអង្គ

ជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ

ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ យំ**

**សច្ចពន្ធគិរិកេ សុមនា ច លគ្គេ យំ តត្ថ**

**យោនកបុរេ មុនិនោ ច បាទំ តំ**

**បាទលញ្ឆនមហំ សិរសា នមាមិ**

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធ

ទ្រង់ប្រតិស្ឋានទុក) លើផ្នូរខ្សាច់ទៀបឆ្នេរនៃស្ទឹង

ឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែល

ព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និង លើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែល ព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះ-បាទនិងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ យោនកបុរេ នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ**

ខ្ញុំសូមនមស្ការអំពីចម្ងាយ នូវស្ថាន

ដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺស្ថាន
លើភ្នំសុវណ្ណមាលិក ១ លើភ្នំសុវណ្ណបពិត ១
លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១
ក្បែរស្ទឹងនម្មទា ១ ។

(ក្រាបថ្វាយបង្គំម្តង)

# គោតមប្រវត្តិ

☞ ខ្ញុំសូមថ្វាយវន្ទា

ព្រះសាស្តាដ៏មានបុណ្យ

និងសូមគោរពគុណ

គ្រាព្រះអង្គចុះចាកឋាន ។

☞ មកចាប់ផ្ទៃមាតា

ស្រីស្រីង្គាររស់កល្យាណ

កាលនោះមហាជនបាន

សុខក្សេមក្សាន្តព្រោះបារមី ។

☞ ក្នុងថ្ងៃព្រហស្បតិ៍អា-

សាធមាសាពេញបូណ៌មី

រកាជាឆ្នាំថ្មី

សុខសិរីដល់ជនា ។

☞ កាលបាន១០ខែហើយ

ព្រះគុណអើយកើតអស្ចារ្យ

នៅនាដងព្រឹក្សា

ឈ្មោះហៅថាព្រៃសាលវ័ន ។

☞ កក្រើកផែនពសុធា

មានទេវតារាប់រយពាន់

ស្ថិតនៅក្នុងតំបន់

នៃឧទ្យានលុម្ពិនី ។

☞ ឆ្នាំចពិសាខនា

ថ្ងៃសុខជាពេញបូណ៌មី

ថ្ងៃនោះព្រះជិនស្រី

ទ្រង់ប្រសូតឥតមានព្រួយ ។

☞ កាលសិទ្ធត្ថក្សត្រា

មានវស្សាដប់ប្រាំមួយ

បិតាបានលើកស្នួយ

អភិសេកនឹងស្រីង្គារ ។

☞ នារីស្រស់កល្យាណា

អ្នកផងបានស្គាល់គ្រប់គ្នា

ថាឈ្មោះនាងពិម្ពា

ស្រស់សោភាលើសលែងក្រៃ ។

☞ កាលនោះក្នុងឆ្នាំឆ្លូវ

ត្រូវថ្ងៃសៅរ៍មានសិរី

អាសាធពេញបូណ៌មី

ក្សត្រាថ្លៃបានសុខា ។

☞ ស្តេចមានព្រះរាជបុត្រ

បរិសុទ្ធភ័ក្ត្រស្រស់ថ្លា

គួរឲ្យព្រះរាជា
ស្តេចជំពាក់ចិត្តពេកក្រៃ
☞ តែទ្រង់បានកាត់ផ្តាច់
ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ
ពីបុត្រថ្លៃមួយគ្រាណា ។
☞ បើបិតាបានត្រាស់
រិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា
ចាកសង្សារណាបុត្រថ្លៃ ។

☞ កាលនោះថ្ងៃព្រហស្បតិ៍

ក្នុងឆ្នាំថោះមានសិរី

អាសាធពេញបូណ៌មី

ក្សត្រាថ្លៃចេញបព្វជ្ជា ។

☞ កាលបានបព្វជ្ជាហើយ

មិនព្រងើយខំឧស្សាហ៍

ធ្វើទុក្ករកិរិយា

គ្មាននរណាធ្វើដូចអ្វី ។

☞ បានត្រាស់ឆ្នាំរកា

ពិសាខាពុធបុណ្ណមី

ជាថ្ងៃព្រះជិនស្រី

មានសិរីឈ្នះក្រុងមារ ។

☞ ត្រាស់ដឹងបានពីរខែ

ទ្រង់គ្មាន់គ្នេរប្រោសទេសនា

ប្រោសបញ្ចវគ្គិយា

នាកណ្តាលដងព្រឹក្សព្រៃ ។

☞ គឺក្នុងឆ្នាំរកា

អាសាធមាសាបុណ្ណមី

ថ្ងៃសៅរ៍ព្រះជិនស្រី

ផ្តើមពោលស្តីធម៌ទេសនា ។

☞ ក៏ជាថ្ងៃកំណើត

សង្ឃបានកើតក្នុងលោកា

សាវ័កព្រះសាស្តា

មានរបូតដល់សព្វថ្ងៃ ។

☞ នាថ្ងៃមួយនោះណា

គួរសោកាណាស់ម្ចាស់ថ្លៃ

គឺថ្ងៃព្រះជិនស្រី

កាត់ព្រះទ័យដាក់សង្ខារ ។

☞ គឺក្នុងថ្ងៃអាទិត្យ

ឆ្នាំម្សាញ់ពិតមាឃមាសា

នៅចំពោះមុខមារ

នាបាវាលចេតិយ ។

☞ បីខែកន្លងទៅ

មិនឈប់នៅយើនយូរអី

ដល់ថ្ងៃព្រះជិនស្រី

ទ្រង់និព្វានចាកលោកា ។

☞ គឺក្នុងឆ្នាំនោះឯង

មានការផ្សេងតែមាសា

គឺខែពិសាខនា

ថ្ងៃអង្គារពេញបូណ៌មី ។

☞ ដោយអំណាចអានុភាព

ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍

នឹកគុណព្រះមុនី

សូត្រប្រវត្តិព្រះសាស្តា ។

☞ សូមឲ្យសម្រេចបុណ្យ

ដែលជាគុណល្អថ្លៃថ្លា

អន្ទោលក្នុងសង្សារ

សូមប្រាថ្នាជួបបណ្ឌិត ។

☞ សូមជួបព្រះសិរអារ្យ

ជាសាស្តាដ៏ពិសិដ្ឋ

សូមចាក់ផ្ទះធម៌ពិត

សមដូចចិត្តប្រាថ្នាហោង ។

( ក្រាបថ្វាយបង្គំម្តង)

## សុភមង្គលគាថា

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ

សព្វទេវតា សព្វពុទ្ធានុភាវេន សោត្ថិ

ហោតុ និរន្តរំ ៗ

ប្រែ : ហោតុ សព្វំ សុមង្គលំ

សុមង្គល គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាងចូរមាន

ដល់ខ្ញុំ, **រក្ខន្តុ សព្វទេវតា** ទេវតាទាំងពួង

ទាំងឡាយចូររក្សានូវខ្ញុំ, **សព្វពុទ្ធានុភាវេន**

ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ, **សោត្ថិ**

**ហោតុ និរន្តរំ** សូមសិរីសួស្តីចូរមានដល់ខ្ញុំ

ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

**ហោតុ ឧលឧ សព្វទេវតា** (ប្រែដូចមុន) ។

**សព្វធម្មានុភាវេន** ដោយអានុភាព

នៃព្រះធម៌ទាំងពួង **សោត្ថិ ហោតុ និរន្តរំ**

(ប្រែដូចមុន) ។

**សព្វសង្ឃានុភាវេន** ដោយអានុភាព នៃព្រះសង្ឃទាំងពួង **សោត្ថិ ហោតុ និរន្តរំ** សូមសិរីសួស្តី ចូរមានដល់ខ្ញុំ ឱ្យបានគ្រប់ពេលកុំបីមានចន្លោះឡើយ ។

(ក្រាបថ្វាយបង្គំម្តង)

## <u>បត្តិទានគាថា</u>

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ**
**កិរិយំ មម កាយេន វាចាមនសា**
**តិទសេ សុគតំ កតំ យេ សត្តា**
**សញ្ញិនោ អត្ថិ យេ ច សត្តា**

អសញ្ញិនោ ភតំ បុញ្ញផលំ មយ្ហំ សព្វេ

ភាគី ភវន្តុ តេ យេ តំ ភតំ សុវិទិតំ

ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន

ជានន្តិ ទេវា គន្ត្វា និវេទយុំ សព្វេ

លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា

មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម

ចេតសាតិ ។

ប្រែ : យំ កិញ្ចិ កុសលកម្មំ

កត្តព្វំ កិរិយំ មម អំពើជាកុសលឯណាមួយ

ដែលខ្ញុំគប្បីធ្វើ, កាយេន វាចាមនសា

ដោយទ្វារទាំង ៣ គឺកាយ វាចា ចិត្ត. **តិវិធេន សុគតំ កតំ** អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យកើតក្នុងឋានត្រៃត្រឹង្សសួគ៌បាន. **យេ សត្តា សញ្ញិនោ អត្ថិ** សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬព្រហ្មដែលជាសត្វមានសញ្ញាក្តី. **យេ ច សត្តា អសញ្ញិនោ** សត្វទាំងឡាយឯណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី. **កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** សត្វទាំងឡាយ

ទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅ នេះចុះ, **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** បុណ្យដែលខ្ញុំបានធ្វើហើយ នោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃ បុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យនេះទៅចុះ, **យេ ច តត្ថ ន ជានន្តិ** មយ៉ាងទៀត បណ្ដាអស់សត្វ ទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវ

បុណ្យដែលខ្ញុំបានធ្វើហើយនោះ **ទេវា គន្ធា និវេទយុំ** សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹង ដល់សត្វទាំងឡាយនោះ ឱ្យបានដឹងផងថាជនឯណោះគេបានធ្វើបុណ្យ ហើយឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ ៗ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេទាំងនោះចុះ.**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា** សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ដែលអាស្រ័យនូវអាហារហើយរស់នៅ. **មនុញ្ញំ ភោជនំ**

**សព្វេ លភន្តុ មម ចេតសាតិ** សត្វ

ទាំងឡាយទាំងអស់នោះ ចូរបាននូវភោជន

ជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្ត

នៃខ្ញុំដែលឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

## ប្រែជាពាក្យកាព្យ

កម្មកុសលឯណា ដែលជាការឥតសៅហ្មង

យើងខ្ញុំបានកសាង ដោយទ្វារកាយវាចាចិត្ត ។

កុសលទាំងអស់នោះ អាចជួយដោះជួយបង្អិត

នាំសត្វឱ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។

សត្វណាមានសញ្ញា មនុស្សទេវតាឬឥន្ទព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្នឹង ។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេវតាទៅប្តឹង ឱ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯនុ៎ះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្ថុជាផ្លូវឆើតឆាយ ។
ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក

ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឱ្យបានកុំខានឡើយ ។

(ក្រាបថ្វាយបង្គំបីដង)

# ឯតទគ្គៈ បាលី និងសេចក្ដីប្រែ

១-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ រត្តញ្ញូនំ យទិទំ អញ្ញាកោណ្ឌញ្ញោ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ ។ (១)

២-មហាបញ្ញានំ យទិទំ សារីបុត្តោ បណ្ដាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើនស្រេចនឹងសារីបុត្ត ។ (២)

**៣-ឥទ្ធិមន្តានំ យទិទំ មហា-**

**មោគ្គល្លានោ** ពួកភិក្ខុអ្នកមានបួទ្ធិ ស្រេចនឹង

មហាមោគ្គល្លាន ។ (៣)

**៤-ធុតវាទានំ យទិទំ មហា-**

**កស្សបោ** ពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់

កិលេស ស្រេចនឹងមហាកស្សបៈ ។ (៤)

**៥-ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ**

ពួកភិក្ខុអ្នកមានទិព្វចក្ខុ ស្រេចនឹងអនុរុទ្ធ ។ (៥)

**៦-ឧច្ចាកុលិកានំ យទិទំ ភទ្ទិយោ**

**កាឡិគោធាយបុត្តោ** ពួកភិក្ខុអ្នកមានត្រកូលខ្ពស់

ស្រេចនឹងភទ្ទិយកាឡិគោធាយបុត្ត ។ (៦)

៧-មញ្ជុស្សរានំ យទិទំ លកុណ្ឌ-

ភទ្ទិយោ ពួកភិក្ខុអ្នកមានសម្លេងពីរោះ

ស្រេចនឹងលកុណ្ឌកភទ្ទិយៈ ។ (៧)

៨-សីហនាទិកានំ យទិទំ

បិណ្ឌោលភារទ្វាជោ ពួកភិក្ខុអ្នកបន្លឺសីហនាទ

ស្រេចនឹងបិណ្ឌោលភារទ្វាជៈ ។ (៨)

៩-ធម្មកថិកានំ យទិទំ បុណ្ណោ

មន្តានីបុត្តោ ពួកភិក្ខុជាធម្មកថិកស្រេចនឹង

បុណ្ណមន្តានីបុត្ត ។ (៩)

**១០-សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ វិភជន្តានំ យទិទំ មហាកច្ចានោតិ**

ពួកភិក្ខុអ្នកចែកសេចក្ដីធម៌ ដែលតថាគតសម្ដែងដោយសង្ខេប ឱ្យពិស្ដារបាន ស្រេចនឹងមហាកច្ចានៈ ។ (១០)

**វគ្គោ បឋមោ** ចប់វគ្គទី ១ ។

**១-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ មនោមយំ កាយំ អភិនិម្មិនន្តានំ យទិទំ ចុល្លបន្ថកោ**

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកនិមិត្តកាយ

សម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចុល្លបន្ថកៈ ប្រសើរជាងគេ ។ (១១)

**✲ -ចេតោវិវដ្ដកុសលានំ យទិទំ ចុល្លបន្ថកោ** ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹងចុល្លបន្ថកៈ ។ (១២)

**២-បញ្ញាវិវដ្ដកុសលានំ យទិទំ មហាបន្ថកោ** ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកប្រាជ្ញា ស្រេចនឹងមហាបន្ថកៈ ។ (១៣)

**៣-អរណវិហារីនំ យទិទំ សុភូតិ** ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចនឹងសុភូតិ ។ (១៤)

✵ -ទក្ខិណេយ្យានំ យទិទំ សុភូតិ

ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចនឹង សុភូតិ ។ (១៥)

៤-អារញ្ញកានំ យទិទំ រេវតោ ខទិរវនិយោ ពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចនឹងរេវតខទិរវនិយៈ ។ (១៦)

៥-ឈាយីនំ យទិទំ កង្ខារេវតោ

ពួកភិក្ខុអ្នកបានឈាន ស្រេចនឹងកង្ខារេវតៈ ។ (១៧)

៦-អារទ្ធវីរិយានំ យទិទំ សោ-ណោ កោលិវិសោ ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងសោណកោលិវិសៈ ។ (១៨)

**៧-កល្យាណវាក្ករណានំ យទិទំ សោណោ កុដិកណ្ណោ** ពួកភិក្ខុអ្នកពោល ពាក្យពីរោះ ស្រេចនឹងសោណកុដិកណ្ណៈ ។ (១៩)

**៨-លាភីនំ យទិទំ សីវលី** ពួកភិក្ខុអ្នកមានលាភ ស្រេចនឹងសីវលី ។ (២០)

**៩-សទ្ធាធិមុត្តានំ យទិទំ វក្កលិ** ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ ស្រេចនឹងវក្កលិ ។ (២១)

**វគ្គោ ទុតិយោ** ចប់វគ្គទី ២ ។

**១-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ សិក្ខាកាមានំ យទិទំ**

**រាហុលោ** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុ អ្នកស្រឡាញ់សិក្ខា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងរាហុល ប្រសើរជាងគេ ។ (២២)

**២-សទ្ធាបព្វជិតានំ យទិទំ**

**រដ្ឋបាលោ** ពួកភិក្ខុអ្នកបួសដោយសទ្ធា ស្រេចនឹងរដ្ឋបាល ។ (២៣)

**៣-បឋមំ សលាកំ គណ្ហន្តានំ យទិទំ**

**កុណ្ឌធានោ** ពួកភិក្ខុអ្នកចាប់ស្លាក ដំបូងបង្អស់ ស្រេចនឹងកុណ្ឌធាន ។ (២៤)

**៤-បដិភាណវន្តានំ យទិទំ**

**វង្គីសោ** ពួកភិក្ខុអ្នកមានបដិភាណ ស្រេចនឹងវង្គីសៈ ។ (២៥)

**៥-សមន្តប្បាសាទិកានំ យទិទំ ឧបសេនោ វង្គន្តបុត្តោ** ពួកភិក្ខុអ្នកមានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹងឧបសេន-វង្គន្តបុត្ត ។ (២៦)

**៦-សេនាសនប្បញ្ញាបកានំ យទិទំ ទព្វោ មល្លបុត្តោ** ពួកភិក្ខុអ្នកក្រាលសេនាសនៈ ស្រេចនឹងទព្វមល្លបុត្ត ។ (២៧)

**៧-ទេវតានំ បិយមនាបានំ**

**យទិទំ បិលិន្ទវច្ឆោ** ពួកភិក្ខុជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ស្រេចនឹងបិលិន្ទវច្ឆៈ ។ (២៨)

**៨~ឧិប្បាភិញ្ញានំ យទិទំ ពាហិយោ ទារុចីរិយោ** ពួកភិក្ខុអ្នកត្រាស់ដឹងរហ័ស ស្រេចនឹងពាហិយទារុចីរិយៈ ។ (២៩)

**៩~ចិត្តកថិកានំ យទិទំ កុមារកស្សបោ** ពួកភិក្ខុអ្នកចេះសំដែងវិចិត្ត ស្រេចនឹងកុមារកស្សបៈ ។ (៣០)

**១០~បដិសម្ភិទប្បត្តានំ យទិទំ**

**មហាកោដ្ឋិតោតិ** ពួកភិក្ខុអ្នកបានបដិសម្ភិទា ស្រេចនឹងមហាកោដ្ឋិតៈ ។ (៣១)

**វគ្គោ តតិយោ** ចប់វគ្គទី ៣។

**១-ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ ពហុស្សុតានំ យទិទំ អានន្ទោ** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុ អ្នកចេះដឹងច្រើន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអានន្ទ ប្រសើរជាងគេ ។ (៣២)

**✵-សតិមន្តានំ យទិទំ អានន្ទោ** ពួកភិក្ខុអ្នកមានស្មារតី ស្រេចនឹងអានន្ទ ។ (៣៣)

✲-គតិមន្តានំ យទិទំ អានន្ទោ

ពួកភិក្ខុអ្នកមានគតិ ស្រេចនឹងអានន្ទ ។ (៣៤)

✲-ធិតិមន្តានំ យទិទំ អានន្ទោ

ពួកភិក្ខុអ្នកមានប្រាជ្ញា ស្រេចនឹងអានន្ទ ។ (៣៥)

✲-ឧបដ្ឋាកានំ យទិទំ អានន្ទោ

ពួកភិក្ខុជាឧបដ្ឋាក ក៏ស្រេចនឹងអានន្ទដែរ ។ (៣៦)

២-មហាបរិសានំ យទិទំ

ឧរុវេលកស្សបោ ពួកភិក្ខុអ្នកមានបរិស័ទច្រើន

ស្រេចនឹងឧរុវេលកស្សបៈ ។ (៣៧)

៣-កុលប្បសាទកានំ យទិទំ

**ភាឡុទាយិ** ពួកភិក្ខុអ្នកញុំាងត្រកូលឱ្យជ្រះថ្លា ស្រេចនឹងកាឡុទាយិ ។ (៣៨)

**៤-អប្បាពាធានំ យទិទំ ពក្កុលោ** ពួកភិក្ខុអ្នកគ្មានអាពាធ ស្រេចនឹងពក្កុលៈ ។ (៣៩)

**៥-បុព្វេនិវាសំ អនុស្សរន្តានំ យទិទំ សោភិតោ** ពួកភិក្ខុអ្នករឭកឃើញ បុព្វេនិវាស ស្រេចនឹងសោភិតៈ ។ (៤០)

**៦-វិនយធរានំ យទិទំ ឧបាលិ** ពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលិ ។ (៤១)

**៧-ភិក្ខុនោវាទកានំ យទិទំ**

**នន្ទកោ** ពួកភិក្ខុអ្នកឱ្យឱវាទភិក្ខុនី ស្រេចនឹង នន្ទកៈ ។ (៤២)

**៨-ឥន្ទ្រិយេសុ គុត្តទ្វារានំ យទិទំ**

**នន្ទោ** ពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹងនន្ទៈ ។ (៤៣)

**៩-ភិក្ខុឱវាទកានំ យទិទំ**

**មហាកប្បិនោ** ពួកភិក្ខុអ្នកឱ្យឱវាទភិក្ខុ ស្រេចនឹងមហាកប្បិន ។ (៤៤)

**១០-តេជោធាតុកុសលានំ យទិទំ**

**សាគតោ** ពួកភិក្ខុអ្នកឈ្លាសវៃក្នុងតេជោធាតុ

ស្រេចនឹងសាគតៈ ។ (៤៥)

**១១-បដិភាណេយ្យកានំ យទិទំ រាធោ** ពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណ ស្រេចនឹងរាធៈ ។ (៤៦)

**១២-លូខចីវរធរានំ យទិទំ មោឃរាជា** ពួកភិក្ខុអ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹងមោឃរាជ ។ (៤៧)

**វគ្គោ ចតុត្ថោ** ចប់វគ្គទី៤។

**១-ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ភិក្ខុនីនំ រត្តញ្ញូនំ យទិទំ**

**មហាបជាបតី គោតមី** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុនីអ្នកដឹងរាត្រី ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងមហាបជាបតីគោតមី ប្រសើរជាងគេ ។ (៤៨)

**២-មហាបញ្ញានំ យទិទំ ខេមា** ពួក ភិក្ខុនីអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងនាងខេមា ។ (៤៩)

**៣-ឥទ្ធិមន្តីនំ យទិទំ ឧប្បលវណ្ណា** ពួកភិក្ខុនីអ្នកមានឫទ្ធិ ស្រេចនឹងនាងឧប្បលវណ្ណា ។ (៥០)

**៤-វិនយធរានំ យទិទំ បដាចារា**

ពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យ ស្រេចនឹងនាង

បដាចារា ។ (៥១)

**៥-ធម្មកថិកានំ យទិទំ ធម្មទិន្នា**

ពួកភិក្ខុនីជាធម្មកថិកា ស្រេចនឹងនាង

ធម្មទិន្នា ។ (៥២)

**៦-ឈាយិនីនំ យទិទំ នន្ទា** ពួក

ភិក្ខុនីអ្នកមានឈាន ស្រេចនឹងនាងនន្ទា។ (៥៣)

**៧-អារទ្ធវីរិយានំ យទិទំ**

**សោណា** ពួកភិក្ខុនីអ្នកមានព្យាយាមបរិបូណ៌

ស្រេចនឹងនាងសោណា ។ (៥៤)

**៨-ទិព្វចក្ខុកានំ យទិទំ សកុលា**

ពួកភិក្ខុនីអ្នកមានទិព្វចក្ខុ ស្រេចនឹងនាងសកុលា ។ (៥៥)

**៩-វិបុលាភិញ្ញានំ យទិទំ ភទ្ទា កុណ្ឌលកេសា** ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស ស្រេចនឹងនាងភទ្ទាកុណ្ឌលកេសា ។ (៥៦)

**១០-បុព្វេនិវាសំ អនុស្សរន្តីនំ យទិទំ ភទ្ទា កបិលានី** ពួកភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងនាងភទ្ទា-កបិលានី ។ (៥៧)

១១-មហាភិញ្ញាបត្តានំ យទិទំ

ភទ្ទា កច្ចានា ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ

ស្រេចនឹងនាងភទ្ទាកច្ចានា ។ (៥៨)

១២-លូខចីវរធរានំ យទិទំ

កិសាគោតមី ពួកភិក្ខុនីអ្នកទ្រទ្រង់ចីវរ ដ៏សៅហ្មង

ស្រេចនឹងនាងកិសាគោតមី ។ (៥៩)

១៣-សទ្ធាធិមុត្តានំ យទិទំ

សិគាលមាតាតិ ពួកភិក្ខុនីអ្នកមានសទ្ធាស៊ប់

ស្រេចនឹងនាង សិគាលមាតា ។ (៦០)

ឯតទគ្គ បញ្ចមោ ចប់វគ្គទី ៥ ។

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ឧបាសកានំ បឋមំ សរណំ គច្ឆន្តានំ យទិទំ តបុស្សភល្លិកា វាណិជា** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់តថាគត ស្រេចនឹងតបុស្សពាណិជ និងភល្លិកពាណិជ ប្រសើរជាងគេ ។ (៦១)

**២-ទាយកានំ យទិទំ សុទត្តោ គហបតិ អនាថបិណ្ឌិកោ** ពួកឧបាសកជាទាយក (អ្នកឱ្យទាន) ស្រេចនឹងសុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។ (៦២)

៣-ធម្មកថិកានំ យទិទំ ចិត្តោ

គហបតិ មច្ឆិកសណ្ឌិកោ ពួកឧបាសក

ជាធម្មកថិក ស្រេចនឹងចិត្តគហបតី ដែលនៅក្នុង

ស្រុកមច្ឆិកសណ្ឌៈ ។ (៦៣)

៤-ចតូហិ សង្គហវត្ថូហិ បរិសំ

សង្គណ្ហន្តានំ យទិទំ ហត្ថកោ អាឡវកោ

ពួកឧបាសកអ្នកសង្គ្រោះបរិស័ទ ឱ្យដោយសង្គហវត្ថុ ៤

ប្រការ ស្រេចនឹង ហត្ថកអាឡវកៈ ។ (៦៤)

៥-បណីតទាយកានំ យទិទំ

**មហានាមោ សក្កោ** ពួកឧបាសកអ្នកឱ្យភោជន

មានរសដ៏ឧត្តម ស្រេចនឹងមហានាមសក្កៈ ។ ( ៦៥)

**៦-មនាបទាយកានំ យទិទំ ឧគ្គោ**

**គហបតិ វេសាលិកោ** ពួកឧបាសក

អ្នកឱ្យភោជនជាទីគាប់ចិត្ត ស្រេចនឹងឧគ្គគហបតី

អ្នកនៅក្នុងក្រុងវេសាលី ។ ( ៦៦)

**៧-សង្ឃុបដ្ឋាកានំ យទិទំ ឧគ្គតោ**

**គហបតិ** ពួកឧបាសកអ្នកបម្រើសង្ឃ ស្រេចនឹង

ឧគ្គតគហបតី ។ ( ៦៧)

**៨-អវេច្ចប្បសន្នានំ យទិទំ សូរោ**

**អម្ពដ្ឋោ** ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងសូរអម្ពដ្ឋ: ។ (៦៨)

**៩-បុគ្គលប្បសន្នានំ យទិទំ**

**ជីវកោ កោមារភច្ចោ** ពួកឧបាសកអ្នកញ៉ាំង បុគ្គលឱ្យជ្រះថ្លា ស្រេចនឹងជីវកកោមារភច្ច ។ (៦៩)

**១០-វិស្សាសកានំ យទិទំ**

**នកុលបិតា គហបតិ** ពួកឧបាសកអ្នកចេះ និយាយ ឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹង នកុលបិតាគហបតី ។ (៧០)

**វគ្គោ ឆដ្ឋោ** ចប់វគ្គទី ៦ ។

**១-ឯតទគ្គំ ភិក្ខវេ មម សាវិកានំ ឧបាសិកានំ បឋមំ សរណំ គច្ឆន្តីនំ យទិទំ សុជាតា សេនានិធីតា** ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកឧបាសិកាអ្នកដល់នូវសរណៈជាបឋម ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងសុជាតាសេនានិធីតា ប្រសើរជាងគេ។(៧១)

**២-ទាយិកានំ យទិទំ វិសាខា មិគារមាតា** ពួកឧបាសិកាជាទាយិកា (អ្នកឱ្យទាន) ស្រេចនឹងនាងវិសាខាមិគារមាតា ។(៧២)

**៣-ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា**

ពួកឧបាសិកាអ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា ។ (៧៣)

**៤-មេត្តាវិហារីនំ យទិទំ សាមាវតី**

ពួកឧបាសិកាអ្នកនៅដោយមេត្តា ស្រេចនឹងនាងសាមាវតី ។ (៧៤)

**៥-ឈាយីនំ យទិទំ ឧត្តរា នន្ទមាតា** ពួកឧបាសិកាអ្នកមានឈាន ស្រេចនឹងនាងឧត្តរានន្ទមាតា ។ (៧៥)

**៦-បណីតទាយិកានំ យទិទំ សុប្បវាសា កោលិយធីតា** ពួកឧបាសិកា

អ្នកឱ្យទានផ្ចិតផ្ចង់ ស្រេចនឹងនាងសុប្បវាសា-កោលិយធីតា ។ (៧៦)

**៧-គិលានុបដ្ឋាកីនំ យទិទំ សុប្បិយា ឧបាសិកា** ពួកឧបាសិកាអ្នកបម្រើ ជម្ងឺ ស្រេចនឹងនាងសុប្បិយាឧបាសិកា ។ (៧៧)

**៨-អវេច្ចប្បសន្នានំ យទិទំ កាតិ-យានី** ពួកឧបាសិកាអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងនាងកាតិយានី ។ (៧៨)

**៩-វិស្សាសិកានំ យទិទំ នកុលមាតា គហបតានី** ពួកឧបាសិកាអ្នក

ចេះធ្វើឱ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនាងនកុលមាតាគហបតានី ។ ( ៧៩)

**១០~អនុស្សវប្បសន្នានំ យទិទំ កាឡី ឧបាសិកា កុររឃរិកាតិ** ពួកឧបាសិកា អ្នកជ្រះថ្លាតាមពាក្យដែលឮតៗគ្នា ស្រេចនឹងនាងកាលីឧបាសិកាកុររឃរិកា ។ ( ៨០)

**វគ្គោ សត្តមោ** ចប់វគ្គទី ៧ ។

## <u>នាទីកំណាព្យផ្សេងៗ</u>

# ចិត្តយើងចិត្តគេ

បើយើងចង់រស់គេក៏ខ្លាចស្លាប់

ខ្លាចភាពឈឺចាប់ខ្លាចទណ្ឌអាជ្ញា

ទោសៈឆេះសិប់គប់វាយប្រហារ

គួរពិចារណាចិត្តយើងចិត្តគេ ។

*ដោយឧបាសិកា* ***ឱម លក្ខណា***

## អត់ធន់ ៣ ប្រការ

អត់ធន់មិនខឹងនឹងអ្នកដទៃ

ជាទានអភ័យគួរឱ្យជ្រះថ្លា

សម្លាប់ទោសៈក្នុងចិត្តអាត្មា

ប្រសើរជាងការមើលឃើញគេខុស ។

អត់ធន់ម្យ៉ាងទៀតនឹងចិត្តលោភៈ

ពេលជាប់ជំពាក់តែងភ្លេចសន្ដោស

បើរឮកទាន់យកសតិឆ្លុះ

ទើបរួចពីទោសតាមឆទ្វារា ។

អត់ធន់ទីបីលះក្ដីមោហះ

ជឿប្រាកដជាក់គ្រប់ពេលវេលា

ថារូបនេះតែងមានចាស់ជរា

ឈឺស្លាប់កម្មពៀរជាប់តាមជានិច្ច ។

*ដោយឧបាសិកា* ***ខិម លក្ខណា***

# អ្វីដែលគួរខ្លាចពិតប្រាកដ

អ្នកខ្លះខ្លាចឈឺខ្លាចចាស់ជរា

ខ្លាចទុក្ខវេទនាខ្លាចពៀរឱ្យផល

ខ្លាចការព្រាត់ប្រាស់ខ្លាចស្លាប់មកដល់

ខ្លាចចោរដំបល់ចូលលួចចូលប្លន់ ។

ខ្លះខ្លាចរន្ទះខ្លាចខ្យល់កួចព្យុះ

ខ្លាចភ្លើងឆេះផ្ទះខ្លាចរោគអាសន្ន

ខ្លាចទាំងដីប្រេះខ្លាចទឹកជំនន់

បួងសួងបន់ស្រន់សូមជៀសឱ្យឆ្ងាយ ។

តាមពិតលោភៈ ទោសៈ មោហៈ

ចោរក្នុងអបលក្ខណ៏នាំធ្លាក់អបាយ

គួរខ្លាចលើសខ្មាំងខាងក្រៅទាំងឡាយ

គ្មានអ្វីអន្តរាយជាងចោរនេះឡើយ ។

*ដោយឧបាសិកា* ***ឌិម លក្ខណា***

# វលកលោកធម៌

វលកលោកធមិ　　បោកចិត្តឱ្យវង្វេង
រំភើបខ្វល់ខ្វាយ　　ជួនព្រួយកើតទុក្ខ
ជួនសុខសប្បាយ　　ជួនព្រាត់ប្រាសឆ្ងាយ
ពីសម្បជញ្ញៈ ។
ជួនមានបុណ្យខ្ពស់　　បានជួបលាភយស
ភ្លេចទោសមរណៈ　　មុជជ្រៅក្នុងភព
ជ្រប់ក្នុងវដ្តៈ　　ទម្រាំដឹងជាក់
ហួសអស់មួយជាតិ ។
ដល់ពេលអស់បុណ្យ　　លាភយសពីមុន
សាបសូន្យចោលម្សៀត　　បើមិនថែចិត្ត

ប្រយ័ត្នមារយាទ មុខជាភ្លាត់ស្នៀត
យំសោកបោកប្រាណ ។
ពេលគេសរសើរ ត្រេកអរគ្រាន់បើ
ចិត្តស្រួលសុខសាន្ត បើគេនិន្ទា
ដូចជារំខាន ក្តៅទ្រាំមិនបាន
រាប់អានមិនយូរ ។
ធម្មតាការពិត នៅក្នុងជីវិត
ទោះល្វីងចត់ជូរ ត្រូវព្រមទទួល
ស្រុះស្រួលបន្ទូរ រសឆ្ងាញ់គ្មានគូ
គឺសច្ចធម៌ ។

*ដោយឧបាសិកា* ***ឌិម លក្ខណា***

# ធម៌គួរពិចារណា ៨ យ៉ាង

ចំពោះបុគ្គលដែលមានបញ្ញា

គួរពិចារណាធម៌ប្រាំបីយ៉ាង

ព្រះឃោសាចារ្យតាក់តែងកសាង

ជាគ្រឿងសំអាងលាងចិត្តឱ្យល្អ។

គិតថាក្តីស្លាប់មានគ្រប់វេលា

ប្រៀបដូចគេយារដាវភ្ជង់នឹងក

រអិលបន្តិចមិនអាចអង្វរ

ដាវមុតកាត់កងាយនឹងស្លាប់បាន។

ពេលសុខរីករាយបានជួបជុំញាតិ

គង់យំព្រោះឃ្លាតមិនយូរប៉ុន្មាន

ជួបព្រាត់កើតស្លាប់ធម៌ពីបូរាណ

អន្ទោលតាមប្រាណកុំស្មានថាទៀង ។

ទោះស្ដេចគហបតីចៀសស្លាប់មិនផុត

សូម្បីព្រះពុទ្ធដល់ពេលក៏យាង

មោគ្គល្លានមានឫទ្ធិជាន់ទេវលោកផ្សៀង

គង់មិនអាចវាងពីការស្លាប់បាន ។

រូបនេះអាចជាសាធារណកាយ

តែងស្លាប់អន្តរាយដោយការរំខាន

គឺទឹកភ្លើងខ្យល់រោគគ្រប់សណ្ឋាន

ទាំងមនុស្សតិរច្ឆានតែងបានសម្ងួស្ស ។

មហាភូតរូបបួនជួនខ្សោយទុព្វល

អាចស្លាប់ដោយខ្យល់បក់ជ្រុលរង្វាស់
រត់មិនស្មើគ្នាដូចជាគេខ្វាស់
បង្កើតទំនាស់ផ្ដាច់អស់សង្ខារ ។
អនិមិត្តោគ្មានគ្រឿងសម្គាល់
ប្រាប់ឱ្យដឹងយល់ថាស្លាប់ពេលណា
ព្យាយាមស្ដាប់ធម៌បដិបត្តិសិក្សា
ទើបកើតបញ្ញា"ព្រមការម្រើត្បូវ" ។
ម្យ៉ាងទៀតគួរយល់ពីអាយុក្ខ័យ
ដែលជនប្រុសស្រីសម័យឥឡូវ
មានត្រឹមចិតប្រាំប្រចាំរដូវ
មិនសមរស់នៅក្នុងក្ដីប្រមាទ ។

ជីវិតកើតស្លាប់រៀងរាល់ខណៈ

មិនគួរបដិបក្ខក្រៅពីសង្ខាត

ព្យាយាមសិក្សាតាមព្រះឱវាទ

សន្សំចិត្តឆ្លាតសំអាតចិត្តបាប ។

*ដោយឧបាសិកា* ***ខិម លក្ខណា***



# ស្តាប់តែម្ខាងនាំអន្តរាយ

ធម៌ឥស្សា នាំវាចា ឱ្យញុះញង់

បើជឿស្លុង ផុងស្មារតី កាត់ក្តីផ្សេង

ស្តាប់តែម្ខាង ស្មានថាពិត មិនគិតផ្សេង

ភាពលំអៀង កៀងចូលផ្លូវ ទៅអបាយ ។

*ដោយឧបាសិកា* ***ខិម លក្ខណា***

# ខ្វះសទ្ធាកំព្រាបុណ្យ

កើតមកជាសត្វលោក

តែងមានរោគប្រចាំកាយ

សើចយំទុក្ខសប្បាយ

រឿងខ្វល់ខ្វាយគ្រប់ៗគ្នា។

នេះមកពីមិនដឹង

ទាំងអស់ហ្នឹងអវិជ្ជា

ឱ្យជាប់អន្ទាក់មារ

ខ្វះសទ្ធាជឿបាបបុណ្យ។

អកុសលចេះតែធ្វើ

គ្មានអើពើរឿងទោសគុណ

ប្រព្រឹត្តការលោភលន់

រងទុក្ខធ្ងន់ទៅអបាយ ។

នរកប្រេតតិរច្ឆាន

ហួសប្រមាណនឹងបរិយាយ

រាប់ម៉ឺនសែនឆ្នាំបួយ

វែងអន្លាយស្គាល់តែទុក្ខ ។

អន្ទោលអស់ច្រើនកប្ប

ការឈឺចាប់មានគ្រប់មុខ

មិនដែលស្គាល់ក្ដីសុខ

រស់ក្នុងគុកនៃវដ្ដៈ ។

លុះបានកើតជាមនុស្ស

គ្មានកិត្តិយសនិងបុណ្យស័ក្តិ

ព្រោះតែសាងអបលក្ខណ៍

កើតខ្ចិនខ្វាក់ស្មើរគ្រប់ជាតិ ។

ដូច្នេះត្រូវចេះគិត

កុំប្រព្រឹត្តតទៅទៀត

អំពើចងអាឃាត

ត្រូវខំឆ្លៀតធ្វើសីលទាន ។

កម្មសាងជាកុសល

នឹងឱ្យផលគ្រប់ជំហាន

ប្រាសចាកការស្រែកឃ្លាន

ដល់និព្វានផុតទុក្ខហោង ។

*ដោយឧបាសក* **លឹម ស្នួស្តិ៍**

## បទលើកតម្កើងព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី
ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស
ហង្សបាទនិងពណ៌ភ្លឺផ្លេក ។
ប្រទេសតូចធំ បានស្ម័គ្រស្មាគម
ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរត្រេក
ប្រសើរពន់ពេកក្រៃកន្លង ។

ធ្វើជាសញ្ញា ទង់ជ័យសាសនា

នៃព្រះសម្ពុទ្ធធំចម្បង

ចូរយើងរាល់គ្នា យកចិត្តចាំចង

នឹកដល់ព្រះអង្គជាអម្ចាស់។

ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា

សុទ្ធសឹងតែជាពុទ្ធសាសនី

ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់

ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា។

សូមសាសនាពុទ្ធ ថ្កុំថ្កើងខ្ពស់ផុត

រុងរឿងវិសុទ្ធថ្លៃថ្លា

ហើយមានជ័យជោគ ផ្សាយពេញលោកា

ដោយជនជ្រះថ្លារាប់ច្រើនលាន។

មានចិត្តស្នេហា គោរពបូជា

ចំពោះព្រះធម៌កល្យាណ

ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ

ប្រាថ្នាចង់បានសេចក្ដីសុខ។

យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត

កាន់ធម៌នឹងបានផុតទុក្ខ

រួបរួមមេត្រី ពីនេះទៅមុខ

ទើបនឹងបានសុខក្សេមក្សាន្តត្រាណ។

ព្រមព្រៀងប្រព្រឹត្ត តាមធម៌សុចរិត

ឆ្ពោះទៅកាន់ឋាននិព្វាន

ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត

ជាតិយើងនឹងបានសោយសុខា។

*និពន្ធដោយ សម្ដេចព្រះសង្ឃរាជ*

***ជ.ណ.ជោតញ្ញាណោ***

# បទសូត្រដាក់ទង់ព្រះពុទ្ធសាសនា

ក្រុមយើងអ្នកកាន់សាសនា

ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី

ទ្រង់មានឆព្វណ្ណរង្សី

គឺព្រះរស្មីទាំងប្រាំមួយពណ៌។

ផ្សាយចេញពីព្រះកាយទ្រង់

រុងរឿងឫទ្ធិរង្គប្រសើរបវរ

ឆ្វៀលឆ្វាត់កាយឆើតឆាយល្អ

ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។

កំណើតនៃព្រះរស្មី

កើតដោយបារមីនៃព្រះភគវា

ធ្វើទានឥតមានរួញរា

កាលដែលនៅជាព្រះពោធិសត្វ ។

រស្មីពណ៌ខៀវនោះណា

កាលឆ្កៀលនេត្រាទ្រង់ដោយចិត្តកាត់

ធ្វើទានដល់ឥន្ទព្រាហ្មណ៍បាត់

កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ ។

រស្មីពណ៌លឿងភ្លឺថ្លា

កាលដែលទ្រង់អារសាច់ផែធ្វើមាស

បិទពុទ្ធរូបភ្លឺឱភាស

ព្រះឥន្ទជាងមាសទ្រង់វ័យបណ្ឌិត ។

រស្មីក្រហមនោះណា

កាលដែលមាតាពស់ខាំស្លាប់ពិត

បទុមស៊ូប្តូរជីវិត

កាត់បេះដូងបិទធ្វើថ្នាំមាតា ។

រស្មីពណ៌សសុទ្ធសាធ

កាលដែលព្រះបាទវេសន្តរក្សត្រា

ឱ្យដីរសសោភា

ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ ។

រស្មីពណ៌ដូចជើងហង្ស

កាលមាតាទ្រង់យក្ខចាប់យកបាន

វិជ្ជាធរអារសាច់ប្រាណ

ឱ្យយក្ខសាមាន្យស៊ីប្តូរជីវិត ។

រស្មីពណ៌ផ្លែកពណ្ណរាយ
កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត
ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម
សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ
ទាំងចាស់កុមារចងចាំទុកអើយ ។

*និពន្ធដោយ សម្តេចព្រះសង្ឃរាជ*

***ជ.ណ.ជោតញ្ញាណោ***

## អ្នកមានឧបការៈជួយពិនិត្យអក្ខរាវិរុទ្ធ

ធម្មាចារ្យ គម្ពីរបញ្ញោ **ទួច សុធី**

ឧទ្ទេសាចារ្យ សីលសំវរោ **ស៊ុំ សាមុត**

សាមណេរ បញ្ញាបរមោ **ឈាត ម៉ុនឆាត**

# សៀវភៅធម៌ដែលបានរៀបរៀង
# ដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

១. អក្ខរវិធី និងធម៌នមស្ការ

២. វលកលោកធម៌

៣. ព្រះធម្មបទ ៣០ គាថា

៤. ប្រយោជន៍ ៣ ប្រការ

៥. ជីវិត (Life)

៦. បងប្អូនជួបគ្នាមួយគ្រាមានន័យ

៧. ឧបមាគុណព្រះរតនត្រៃម្ភៃពីរប្រការ ( កំណាព្យ)

៨. អភិធម្មត្ថសង្គហៈ បរិច្ឆេទទី៤

៩. អភិធម្មសង្គណី តិកមាតិកាសង្ខេប

១០.ជីវិតពិតជាត្រូវការធម៌

១១.តើនរកមានដែរឬទេ ?

# កម្មវិធីផ្សព្វផ្សាយព្រះធម៌

## សម្តែងដោយ ភិក្ខុវជិរប្បញ្ញោ សាន សុជា

| ខេត្ត-ក្រុង | ស្ថានីយវិទ្យុ | វេលាផ្សាយ |
|---|---|---|
| ភ្នំពេញ | FM 102.50 MHz | ៥.១០ am ⇨ ៥.៤០ am |
| សៀមរាប | FM 102.50 MHz | ៥.៣០ am ⇨ ៦.០០ am |
| កំពង់ចាម | FM 107.70 MHz | ៥.០០ am ⇨ ៥.៣០ am |
| | FM 107.70 MHz | ៧.០០ pm ⇨ ៨.០០ pm |
| កំពង់ធំ | FM 98.30 MHz | ៥.០០ am ⇨ ៥.៣០ am |
| | FM 88.50 MHz | ៨.០០ pm ⇨ ៨.៣០ pm |
| កំពត | FM 99.70 MHz | ៦.៣០ pm ⇨ ៧.០០ pm |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទាន ឈ្នះអស់ទានទាំងពួង

# កម្មវិធីផ្សព្វផ្សាយព្រះធម៌

## សម្ដែងដោយភិក្ខុវជិរប្បញ្ញោ សាន សុជា (ត)

| | | |
|---|---|---|
| បន្ទាយមានជ័យ | FM 99.00 MHz | ៦.00 am ⇨ ៦.៣0 am |
| ពោធិ៍សាត់ | FM 100.50-MHz | ៦.៣0 pm ⇨ ៧.00 pm |
| | FM 98.50 MHz | ៧.00 pm ( ថ្ងៃសីល) |
| តាកែវ | FM 92.50 MHz | ៦.៣0 pm ⇨ ៧.00 pm |
| កំពង់សោម | FM 100.50 MHz | ៥.00 am ⇨ ៥.៣0 am |
| | | ៥.៣0 am ⇨ ៦.៣0 am |
| | FM 93.00 MHz | ៨.៣0 pm ⇨ ៩.00 pm |
| បាត់ដំបង | FM 88.50 MHz | ៩.00 pm ⇨ ១0.៣0 pm |

**សុស្សូសំ លភតេ បញ្ញំ**

ការស្ដាប់ ( ធម៌ ) ដោយល្អ រមែងបាននូវបញ្ញា

# សុខពិត



នៅពេលណាដែលចិត្ត សុខស្ងប់ពិតដោយនេក្ខម្មៈ

ទើបលែងត្រូវពឹងពាក់ លាភយសសក្តិមាសប្រាក់ទៀត

ដោយឧបាសិកា ខ្ញឹម លក្ខណា

ISBN-9789996357947

9 789996 357947